# និយមន័យនិមិត្តសញ្ញា
# សម្លេងខ្មែរដើម្បីប្រជាធិបតេយ្យ

កំណាព្យពាក្យ៨

១- **វង្ស់ពីរ**អម ជាធម៌គូគ្នា ជាតិខ្មែរកម្ពុជា ជំរុញសាមគ្គី
មិនប្រកាន់បក្ស ជាមួយជាពីរ **យាយជីតាជី គ្រហស្ថព្រះសង្ឃ** ។

២- **ក្មេងចាស់ប្រុសស្រី** ក្នុងសកលលោក ត្រូវតែហៅមក រួបរួមចងក្រង
ចងជាចង្កោម តាមគោលបំណង ដែលយើងប៉ុនប៉ង ដើម្បីជាតិសុខ ។

៣- រំដោះជាតិខ្មែរ ពីយួនចង្រៃ សព្វថ្ងៃចូលមក ទន្រ្ទានពេញស្រុក
ដោយសារមេខ្មែរ ចិត្តខ្មៅគគ្រុក បើកមុខហុចដៃ ប្រល័យជាតិខ្មែច ។

៤- **ខ្មែរក្នុងខ្មែរក្រៅ ប្រទេសតូចធំ** ដោះដូរសង្គម ជាស្ពានសេដ្ឋកិច្ច
ចេះចែកគ្នារស់ តាមតួភារកិច្ច គ្មានល្បិតកិច្ចកល ផ្តល់យុត្តិធម៌ច្បាស់ ។

៥- សង្គមជាតិមួយ តែងមាន**កម្មពីរ** **មានញីមានឈ្មោល មានស្តើងមានក្រាស់**
**មានល្អអាក្រក់ មានក្មេងមានចាស់** **មានព្រិលមានច្បាស់ មានតូចមានធំ** ។

៦- **មានខ្ពស់មានទាប មានរាបមានទួល** **មានលារមូល កម្ទោះក្រមុំ**
នេះហៅ**ធម៌គូ** នៅក្នុងសង្គម តែខ្មែរយើងសុំ កុំរស់ក្នុងពាល ។

៧- សង្គមខ្លះអ្នកខូច ច្រើនជាងអ្នកល្អ សីលធម៌កម្រ បវរជ្រៅជ្រាល
ពិបាកធ្វើថាស្រួល បើធ្វើបានព្រាល ដូចជាលដាក់ទឹក តែងលិចវិញអស់ ។

៨- សង្គមណាអ្នកល្អ ច្រើនជាងអ្នកខូច ទោះតូចទោះធំ តែងបានលូតលាស់
ពលរដ្ឋសេរី សេដ្ឋកិច្ចសក្តិយស ល្បីទាំងកេរ្តិ៍ឈ្មោះ ពិរោះថ្កុំថ្កើង ។

៩- ឥឡូវមាតុភូមិ កំពុងគ្រោះថ្នាក់ ធ្លាក់ក្នុងអន្ទាក់ នឹងមេឈាមឈ្លើង
ដឹកនាំប្រទេស ក្រោមបាទអាញៀង ខ្មែរអើយក្រោកឡើង កុំនៅកន្តើយ ។

១០- មានតែយើងទេ ទើបជាតិយើងរស់ បើខ្មែរយើងឈ្លោះ គ្រោះដល់ស្លាប់ហើយ
ជាតិនឹងអាប់ឱន យួនត្រួតបង្ហើយ កុំសង្ឃឹមឡើយ ដេកលង់លក់ណា ។

១១- សមាគមអង្គការ ត្រូវការចម្រុះ គឺ**ធនធានមនុស្ស និងថវិកា**
វីធនធានមនុស្ស គឺញាណបញ្ញា ឯថវិកា សម្រាប់រុញច្រាន ។

១២- ចក្រទាំងពីរនេះ ឲ្យសមាគមដើរ អាចធ្វើដំណើរ ដើរទៅមុខបាន
តែមេដឹកនាំ ត្រូវមានសន្តាន ចិត្តស្មើស្មោះស្មាន្ត រុញឲ្យសុះសាយ ។

១៣- សម្លេងខ្មែរដើម្បីប្រជាធិបតេយ្យ ខ្មែរត្រូវពួតដៃ ទាំងជិតទាំងឆ្ងាយ

បំពងសម្លេង ឲ្យឮខ្ទរខ្ទាយ ប្រាប់លោកទាំងឡាយ ដែលរស់កុះករ ។

១៤- **ដើរត្រូវមានបី សម្ដីមានបួន** ពាក្យចាស់ចាប់ជួន មានន័យបវរ
**នីតិបញ្ញត្តិ** កើតច្បាប់ខ្មៅស អាក្រក់ល្អឲ្យខ្មែរ ដើរតាមបន្ទាត់ ។

១៥- **នីតិតុលាការ** បកស្រាយគ្រប់ច្បាប់ ជម្រះចងចាប់ តាមធម៌មធ្យ័ត
ផ្នែកអនុវត្តិ **នីតិប្រតិបត្តិ** ដើរតាមបញ្ញត្តិ ធម្មនុញ្ញទ្រឹស្ដី ។

១៦- សម្ដីទី៤ ក៏គឺ**ពលរដ្ឋ** គ្រប់ខេត្តជនបទ មានសិទ្ធិសេរី
ដែលជាគ្រឹះធំ ប្រជាធិបតេយ្យ អ្នក៣ខាងដើម យកជាគោលការណ៍ ។

១៧- ពួកអ្នកទាំង៣ ឯករាជ្យម្ចាស់ការ គ្មានអ្នកណាមួយ ឈ្លានពានអ្នកណា
ឬមួយជ្រៀតជ្រែក ទំនាស់កិច្ចការ ដោយសារបក្សពួក ឬគ្មានអនុញ្ញាត ។

១៨- ខាងប្រតិបត្តិ គ្មានសិទ្ធិដកដេញ បញ្ជូលបញ្ចេញ ខាងសភាជាតិ
ឲ្យធ្វើតាមខ្លួន ព្រោះតែយល់ញាតិ នេះហៅខុសឃ្លាត គោលប្រជាធិបតេយ្យ ។

១៩- ឃើញត្រូវថាត្រូវ ឃើញខុសថាខុស បើមានកំហុស រួចកែជាថ្មី
ទើបហៅជួយគ្នា ស្មោះស្ម័គ្រភក្ដី បំបាត់អប្រិយ ឲ្យអស់ទុក្ខព្រួយ ។

២០- យល់ញាតិឃ្លាតច្បាប់ ជាពុតអាក្រក់ ដីសែនលាមក មហាពុករលួយ
បង្វែរពីរបី ឲ្យទៅជាមួយ មិនជាជំនួយ ដល់ពលរដ្ឋរាស្ត្រ ។

២១- ក្នុងលោកគេស្អប់ ពួកអ្នកជិះជាន់ លួចប្លន់បំភាន់ បំបិទភ្នែករាស្ត្រ
យើងអ្នកដឹកនាំ ត្រូវមានកេរ្តិ៍ខ្មាស់ មិនត្រូវផ្ដេសផ្ដាស់ ត្រូវជួយសង្គម ។

២២- ធ្វើស្រែពឹងទឹក ធ្វើសឹកពឹងបាយ អ្នកធ្វើនយោបាយ ពឹងរាស្ត្រជាធំ
មិនត្រូវបោករាស្ត្រ ឲ្យកើតគំនុំ ទើបប្រមូលផ្ដុំ ជួបជុំគ្រួសារ ។

២៣- បើរាស្ត្រចូលចិត្ត នយោបាយចម្រើន សេដ្ឋកិច្ចក៏កើន ព្រោះរាស្ត្រគាំពារ
ជាតិបានសុខសាន្ត សុខដុមរមនា ជាតិផងនានា ក៏គេគ្រាំទ្រ ។

២៤- ធ្វើអ្វីឲ្យមាន គោលការណ៍ច្បាស់លាស់ យកមកពិគ្រោះ ត្រង់ទៅត្រង់មក៏
កន្លែងណាខុស យើងកែលម្អ រួចហើយបន្ត ធ្វើឲ្យខ្ពស់ឡើង ។

២៥- **ទង់ជ័យសង្វាង** តំណាងជាតិខ្មែរ ដែលធ្លាប់ពូកែ មហានគរថ្កើង
ដូច្នេះត្រូវរួម ពួតដៃគ្នាឡើង តម្កើងទង់ជ័យ ឲ្យរស់អង្វែង ។

២៦- កុំបានតែពាក្យ ត្រគាកស្លាប់ស្លក មនុស្សយើងក្នុងលោក ត្រូវធ្វើជាក់ស្ដែង
ត្រូវរួមផ្សំគ្នា ខ្ញុំយើងគេឯង ព្រះពុទ្ធសម្ដែង ប្រាប់ប្រងទេសនា ។

២៧-- ទសពិធរាជធម៌ មេសាមគ្គីធម៌ គតិបវរ ដោយករុណា
អនុគ្រោះគ្នីគ្នា ដោយក្ដីមេត្តា មានព្រហ្មវិហារ គួរឲ្យរាប់អាន ។

២៨- ធម៌បីរួមផ្សំ ជា**សាមគ្គីធម៌** **ព្រហ្មវិហារបវរ សង្គហៈ**រុញច្រាន
លះបង់**អគតិ** ជាផលកល្យាណ ទើបបានសម្រេច សាមគ្គីក្ដីសុខ ។

២៩- **កណ្ដាលព្រហ្មមុខប្អូន** **ព្រហ្មវិហារ**សញ្ញា **មេត្តា**ប្រាថ្នា ឲ្យគេបានសុខ
**ករុណា**អាណិត ជួយគេរួចទុក្ខ **មុទិតា**គិតទុក ចិត្តត្រេកត្រអាល ។
៣០- សប្បាយរីករាយ បើគេបានល្អ **ឧបេក្ខា**ត្រេកអរ ចិត្តជាកណ្ដាល
មិនមានច្រណែន និទ្ទារាលដាល ចាក់ចុចអុជអាល ឲ្យគេក្ដៅផ្សា ។
៣១- **ពីរសង្គហធម៌** ក៏ចែកជាបួន **ទាន**ឲ្យទ្រព្យខ្លួន ទៅជាលាភា
អាមិសទានធម្មទាន ដល់អ្នករាល់គ្នា **បិយវាចា** ពោលពាក្យពិរោះ ។
៣២- **អត្ថចរិយា** ផ្ដល់ជាប្រយោជន៍ ដែលមិនអសោចិ៍ ដល់អ្នកទាំងអស់
**សមានត្តតា** ធ្វើខ្លួនជាមនុស្ស ស្មគ្រស្មើចិត្តស្មោះ មិនប្រកាន់អញ ។
៣៣- **បីអគតិបួន** ជាអលាភា **ឆន្ទាគតិ** រាប់ព្រោះស្រឡាញ់
**ទោសា**លំអៀង ព្រោះស្អប់ខ្ពន់ខ្ពាញ់ គឺអញនិយម បង្កើតពួកបក្ស ។
៣៤- **មោហាគតិ** លំអៀងព្រោះល្ងង់ គំនិតខ្ជិនខ្ជង់ គ្មានពាក្យសច្ចៈ
ងងឹតងងល់ ដូចជាមនុស្សខ្វាក់ ចចេសអនត្ស គ្មានហេតុគ្មានផល ។
៣៥- **ភយាគតិ** លំអៀងព្រោះខ្លាច តាមគេបន្ទាច ងាករេតាមខ្យល់
នេះហៅអគតិ មិនត្រូវខ្វាយខ្វល់ អាចនាំអំពល់ សង្គមនានា ។
៣៦- សូមសាកសរុប ធម៌លើទាំងបី តាមដូចទ្រឹស្ដី ឲ្យកើតសាមគ្គា
យើងគេគោរព អនុវត្តិគ្រប់គ្នា តាមពុទ្ធមាគ៌ា ទ្រង់ប្រោសគ្រប់ប្រាណ ។
៣៧- បើមេដឹកនាំ យើងទាំងអស់គ្នា មាន**ព្រហ្មវិហារ** នៅក្នុងសណ្ដាន
**មេត្តាករុណា** ធម៌អាចរុញច្រាន ឲ្យធ្វើជា**ទាន** ហៅ**សង្គហធម៌** ។
៣៨- **សម្ដីផ្អែមល្ហែម** រាប់រកញាតិមិត្ត **គ្មានគិតប្រវញ្ច** **តាមគតិធម៌**
មិនព្រោះ**ស្រឡាញ់** **ស្អប់**រាប់ទៅមក៏ ហើយមិន**កៀរគរ** **ទារយកប្រយោជន៍** ។
៣៩- បើបុគ្គលណា មានធម៌ទាំងបី ទោះប្រុសទោះស្រី ស្លាប់ទៅជាខ្មោច
នៅតែល្បីឈ្មោះ គ្មានកេរ្តិ៍អសោចិ៍ រស់មិនហិនហោច មានគេរាប់អាន ។
៤០- បើយើងម្នាក់ៗ ធ្វើទាំងអស់គ្នា នឹងមានសាមគ្គា ជាក់ជាមិនខាន
ទេសនោះស្រុកនោះ គ្មានអ្វីរំខាន នឹងបានសុខដុម គ្មានអ្វីប្រៀបបាន ។
៤១- តែឯអ្នកធ្វើ ត្រូវមានសីលធម៌ ជាធម៌បវរ ប្រចាំក្នុងប្រាណ
ជម្រះបាបកម្ម ពីខន្ធសណ្ដាន កាន់សីលឲ្យបាន ប្រចាំក្នុងខ្លួន ។
៤២- ដូច្នេះសមាគម ត្រូវតែមានមេ អ្នកគិតគ្មាន់គ្នេរ ចេះច្បាប់ចេះក្បួន
ជួយដឹងណែនាំ កូនចៅផងខ្លួន ឲ្យបានមាំមួន កុំនាំធ្លាក់ជ្រាំ ។
៤៣- មេមិនសំដៅ តែប្រធានទេ យើងគេជាក្រុម គណៈអ្នកដឹកនាំ
គោរពតួនាទី មិនមែនពុលព្រាំ ដឹកនាំញាំញី តែជាតិសាស្ដ្រឯង ។
៤៤- មេចេះគិតគូរ គ្រប់ជ្រុងគ្រប់ជ្រោយ គិតមុខគិតក្រោយ ហើយចេះថ្លឹងថ្លែង

ចេះប្រើមនុស្សម្នា  មិនខ្លាចលីសែង  ចេះគិតកោតក្រែង  ចេះឆ្លៀតលួកល ។

៤៥- អ្នកកាចជាខ្នង  អ្នកកោងជាគ្នា  អ្នកណាល្អជា  ទុកជាទស្សន៍ទ
អ្នកអួតគឃរ  ជាព្រួញជន្ទ  ឈើណាវៀចងរ  ទុកជាចន្ទោល ។

៤៦- វៀចធ្វើជាកង់  ត្រង់ធ្វើជាកាំ  ឈើណាប្រែសស្រាំ  ធ្វើស្នៀតបង្គោល
ខ្ទឹមធ្វើជាដុំ  ពកធ្វើកូនគោល  ខ្ទះធ្វើចន្ទល់  ជ្រុំជ្រែងក្នុងក្រៅ ។

៤៧- មេចេះដឹកនាំ  មេប្រជាធិបតេយ្យ  កូនមិនប្រល័យ  កូនថែបំពៅ
ហៅថាគ្រូធំ  មេបាតាព្រះចៅ  តែព្រះប្រដៅ  ពាលកុំសេពគប់ ។

៤៨- វីធម៌សាមគ្គី  សូមសង្ខេបខ្លី  កវីលើកយក  ធម៌មេបង្គ្រប់
ដែលខ្ញុំយើងគេ  តែងតែសម្អាព  ទាំងយប់ទាំងថ្ងៃ  ធ្លាប់ឮជោគជាំ ។

៤៩- គឺសូមបរិយាយ  **ទសពិធរាជធម៌**  ជាធម៌បវរ  នៃអ្នកដឹកនាំ
អ្នកជួយស្រុកទេស  មិនឲ្យធ្លាក់ជ្រាំ  ជួយនាំអ្នកតាម  ឲ្យបានជោគជ័យ ។

៥០- ទសៈគឺ១០  ពិធៈត្រង់ពិត  រាជៈអ្នកគិត  ពិនិត្យរំពៃ
សំឡឹងគ្រប់ជ្រោយ  គយគន់គ្រប់ន័យ  អ្នកឲ្យក្តីសុខ  ជាតិនិងគ្រួសារ ។

៥១- ធម្មៈគឺធម៌  បន្ទាត់ក្រមច្បាប់  គឺបទប្បញ្ញត្តិ  ដ៏មានខ្លឹមសារ
រួមមកគឺ**ច្បាប់  មាន១០ប្រការ**  **នៃជននានា  ដែលដឹកនាំគេ** ។

៥២- **មួយគឺទានៈ**  ការធ្វើអំណោយ  ដល់អ្នកទន់ខ្សោយ  មិនរើសមុខទេ
ទានទ្រព្យរបស់  ទានធម៌ធម្មេ  ឲ្យគេបានចេះ  ពិសេសការសិក្សា ។

៥៣- **ពីរគឺសីលៈ**  សីល៥ជានិច្ច  ហើយក៏មិនភ្លេច  សីល១០ប្រការ
គឺកាន់សីល១០  មួយដងមួយកាល  រក្សាខ្ជាប់ខ្ជួន  មិនឲ្យស្រាំស្រួយ ។

៥៤- **បីគឺបរិច្ចាគ**  លះទ្រព្យផងខ្លួន  ជួយជាតិឲ្យមួន  មិនពុករលួយ
មិនគេញប្រវញ្ច  បន្លំជំនួយ  បើគេឲ្យស្ងួយ  ជួយជាតិទាំងអស់ ។

៥៥- **បួនអាជ្ជវៈ**  សច្ចៈទៀងត្រង់  មិនវៀចខ្វៀនខ្វង់  លាក់ពុតមិនស្មោះ
ហុតទឹកមើលកាក  ពាលក្នុងអាវក្រោះ  មិនចេះឡេះឡោះ  ឧបាយបោកប្រាស់ ។

៥៦- **ប្រាំមទ្ទវៈ**  រាបសារសុភាព  ស្លូតបូតរៀងរាប  ដឹងក្មេងដឹងចាស់
គប់ប្រាជ្ញលះពាល  ចេះច្បាប់ជាក់ច្បាស់  មិនកោងផ្តេសផ្តាស់  ដូចជនពាលា ។

៥៧- **ប្រាំមួយតបៈ**  មានចិត្តកាយស្ងប់  អ្នកចេះរំងាប់  ដើរតាមធម្មា
កាន់សីលប្រាំបី  តាមកាលវេលា  ពុះពារឧបសគ្គ  តស៊ូមែនទែន ។

៥៨- **ប្រាំពីរអក្កោធនៈ**  មិនក្តៅក្រហាយ  នឹងអ្នកជិតឆ្ងាយ  មិនចេះច្រណែន
នឹងអ្នកដទៃ  ក្រមានម៉ឺនសែន  ជម្រុញបោកបែន  ឲ្យចេះវិជ្ជា ។

៥៩- **ប្រាំបីអវិហឹសា**  មិនចេះបៀតបៀន  បើសិនទិទៀន  ក៏ឲ្យល្អជា
ទាំងកូនក្មួយចៅ  និងជននានា  មិនចងកម្មពៀរ  ឲ្យគេត្រេងត្រាង ។

៦០- **ប្រាំបួនខន្តី** មានក្តីអត់ធន់ មិនចេះទម្រន់ អាងលេសច្រើនយ៉ាង
គ្មានក្តៅត្រជាក់ តិចតួចជាតាង ហើយអាងថ្ងៃពេក ខ្ជិលរៀនធ្វើការ ។
៦១- **ដប់អវិរោធនះ** យកច្បាប់ជាធំ មិនគេញបន្ទំ បំភ្លៃវដ្ឋា
ដឹកនាំស្រុកទេស តាមតែខ្លួនថា អាត្មានិយម ព្រោះអញអ្នកធំ ។
៦២- ឱសភាខ្ញុំទូរ. គ្រូព្រំ-សាពោន យកយោនធម៌នេះ មកជូនសង្គម
ហើយខ្ញុំមើលតាម វចនានុក្រម អម្ចាស់ជួន-ណាត ឲ្យត្រូវក្រិត្យា ។
៦៣- មនុស្សសឹងគ្រប់រូប ដឹងធម៌នេះច្រើន តែមិនចម្រើន ចេះចាំវគ្គឃ្លា
ពេលនេះខ្ញុំលើក មកចងកាព្យា ជូនយើងគ្រប់គ្នា ចេះចាំយល់ន័យ ។
៦៤- ខ្ញុំសូមអភ័យ បើមានខុសឆ្គង អត់ទោសឲ្យផង កុំចាប់ទោសពៃរ៍
សូមជួយចែកចាយ ជូនជនប្រុសស្រី កវីសូមអរ អំណរប្រចាំ ។
៦៥- សូមឧទ្ទិសកាព្យ ដល់លោកវាគ្មិន គឺសំ-ប៊ូរិន្ទ បានអនិច្ចកម្ម
សូមលោកបានសុខ ហើយជួយបែរផ្តាំ និងជួយថែទាំ ដល់ជាតិខ្មែរផង ។
៦៦- បើចង់យល់ច្រើន សូមមើលក្បួនផ្សេង មានចែងច្រើនណាស់ ច្រើនក្រែកន្ទង
តែក្បួនសាមគ្គី ខ្ញុំបានចងក្រង ជាកាព្យណែងណង នៅក្នុងក្បួនមួយ ។
៦៧- ហៅ**សម្ព័ន្ធខ្មែរអន្តរជាតិ** មានលាតត្រដាង គ្រាន់ជាជំនួយ
សូមអានកំសាន្ត បំបាត់ទុក្ខព្រួយ គ្រាន់ជួយបញ្ញា បង្អស់មោហៈ ។

ថ្ងៃទី៣១ខែធ្នូឆ្នាំ២០១២
គឹម-ច័ន្ទវង្ស, PhD, BA



chanvongkim@yahoo.com, 206-713-2083
គុរង្វាន់សុតន្តប្រីជាឥន្ទ ជំនាន់ទី១ ឆ្នាំ១៩៧៣
ទំនាក់ទំនងការបរទេស សម្លេងខ្មែរដើម្បីប្រជាធិបតេយ្យ
ពិនិត្យដោយគណៈកម្មាធិការនាយក សខប

# និយមន័យនិមិត្តសញ្ញា
# សម្លេងខ្មែរដើម្បីប្រជាធិបតេយ្យ

សម្រាយ

១- **រង្វង់ពីរ:** ធម៌គូគឺ ប្រុសស្រី ក្មេងចាស់ តូចធំ វែងខ្លី គ្រហស្ថព្រះសង្ឃ.... ។

២- **ដើរត្រូវមានបី សម្តីមានបួន: នីតិបញ្ញត្តិ នីតិតុលាការ នីតិប្រតិបត្តិ ពលរដ្ឋ**គឺប្រជាធិបតេយ្យ ។

៣- **ទង់ជ័យសង្វាង:** តំណាងជាតិខ្មែរ។

៤- **កណ្តាលព្រហ្មមុខបួន: ព្រហ្មវិហារ៤:** ១-មេត្តា ២-ករុណា ៣–មុទិតា ៤-ឧបេក្ខា

៥- **សង្គហធម៌៤:** **១-ទាន ២-បិយវាចា ៣-អត្ថចរិយា ៤-សមានត្តតា**

៦- **អគតិបួន:** **១-ឆន្ទាគតិ ២-មេហាគតិ ៣-ទោសាគតិ ៤-ភយាគតិ**

៧- **ទសពិធរាជធម៌:** **ច្បាប់អ្នកដឹកនាំ១០ប្រការ**

| | | |
|---|---|---|
| **១–** | **ទាន:** | **អំណោយ....** |
| **២–** | **សីល:** | **សីល៥, សីល៨.....** |
| **៣–** | **បរិច្ចាគ:** | **លះបង់...** |
| **៤-** | **អាជ្ជវ:** | សច្ចៈទៀងត្រង់... |
| ៥- | **មទ្ទវ:** | សុភាពរាបសារ... |
| ៦- | **តប:** | មានចិត្តកាយស្ងប់.... |
| ៧- | **អក្កោធន:** | មិនក្តៅក្រហាយ ... |
| ៨- | **អវិហឹសា** | មិនចេះបៀតបៀន.... |
| ៩- | **ខន្តី** | មានក្តីអត់ធន់.... |
| ១០- | **អវិរោធន:** | យកច្បាប់ជាធំ..... |

ថ្ងៃទី៣១ខែធ្នូឆ្នាំ២០១២

គឹម-ច័ន្ទវង្ស, PhD, BA



chanvongkim@yahoo.com, 206-713-2083

គុរង្វាន់សុតន្តប្រីជាឥន្ទ ជំនាន់ទី១ ឆ្នាំ១៩៧៣

ទំនាក់ទំនងការបរទេស សម្លេងខ្មែរដើម្បីប្រជាធិបតេយ្យ

ពិនិត្យដោយគណៈកម្មាធិការនាយក សខប